ភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ១៩៩៤

# សារាចរ

## សារាចរលេខ ០២ សរ.អច. ស្តីពីការ
## រក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៅពេលប្រលង

កន្លងមកការរៀបចំប្រលង នៅដំណាច់ឆ្នាំសិក្សា បានទទួលលទ្ធផលមួយក៏រីកធំហើយ ប្រៀបធៀបទៅនឹងលទ្ធភាពដែលយើងមាន តែក៏នៅមានចំណុចសេសសល់ខ្វះខាតខាត្រូវកែលំអ ។

ដូចនេះដើម្បីអោយការប្រលងដំណាច់ឆ្នាំសិក្សា ១៩៩៣-១៩៩៤ គឺការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ដែលនឹងចាប់ផ្តើមពីថ្ងៃទី ១៦ មិថុនា ឆ្នាំ ១៩៩៤ ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ពីថ្ងៃទី ១២ កក្កដា ឆ្នាំ ១៩៩៤ និងការប្រលងវិញ្ញាបនប័ត្របឋមសិក្សា ពីថ្ងៃទី ២១ មិថុនា បានប្រព្រឹត្តទៅល្អប្រសើរ ធានាបានភាពយុត្តិធម៌ ស្អាតស្អំជូនបេក្ខជន និងមាតា បិតា ឬអាណាព្យាបាលបេក្ខជន ក្នុងន័យលើកកំពស់កិត្យានុភាពនៃការដឹកនាំរបស់រាជរដ្ឋាភិបាលយើង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវចាត់តាំងអប់រំ អោយបានទូលំទូលាយជូនមន្ត្រីរាជការ បុគ្គលិក កម្មករ ប្រជារាស្ត្រទូទាំងប្រទេសអោយយល់លក្ខការណ៍នៃការប្រលង ដែលផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចៀសវាងការអនុវត្តនូវប្រការណាមួយផ្ទុយ និងបទបញ្ញត្តិនៃការប្រលង ឬធ្វើអោយខូចសណ្តាប់ធ្នាប់របៀបរៀបរយ បង្កភាពស្មុគស្មាញ ក្នុងពេលប្រលង ។ សូមណែនាំអប់រំបងប្អូន កូនចៅទាំងអស់អោយមានលំនឹង និងទុកចិត្តថា រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា នឹងយកចិត្តទុកដាក់ ទទួលខុសត្រូវចំពោះការរៀបចំប្រលងអោយបានល្អប្រសើរជូនមាតាបិតាអាណាព្យាបាលរបស់សិស្ស និងសិស្សានុសិស្សទាំងអស់ ជាពិសេសសូមបញ្ឈប់ជាដាច់ខាត នូវការធ្វើអន្តរាគមន៍ និងសូកប៉ាន់ ដល់គណៈមេប្រយោគ ដើម្បីអោយកូនចៅ ឬកូនក្មួយរបស់ខ្លួនបានជាប់ដែលផ្ទុយ នឹងភាពយុត្តិធម៌ និងសមត្ថភាពសាម៉ីខ្លួន ។

២- ចំពោះមន្ត្រីរាជការ នគរបាល យុទ្ធជន ដែលមានភារកិច្ចសហការ រក្សាការពារសណ្តាប់ធ្នាប់ របៀបរៀបរយតាមមណ្ឌលប្រលងនីមួយៗ ត្រូវអនុវត្តតាមភារកិច្ចរបស់ខ្លួន អោយបានមឺត់ចត់ត្រឹមត្រូវ ជួយធ្វើអោយការងារប្រលងប្រព្រឹត្តទៅក្នុងប្រក្រតីភាព និងប្រសិទ្ធភាព ចៀសវាងដាច់ខាត ការអនុវត្តអ្វីដែលធ្វើអោយខូចវិន័យ និងសណ្តាប់ធ្នាប់ នៃការប្រលង ។

រាជរដ្ឋាភិបាល សង្ឃឹមយ៉ាងកត់កៀបំផុតចំពោះក្រសួង រដ្ឋលេខាធិការដ្ឋានទាំងអស់ នឹងលើកកំពស់អនុវត្តសារាចរណែនាំនេះអោយបានជោគជ័យ ។

ជ.រាជរដ្ឋាភិបាល

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *